ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


២៧-៤-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៤១៣/៤១៤ ស្ដីពី ការដំឡើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ ជូនសពនាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ០២ រូប ៤៣១៩

២៧-៤-២០១៣ -ព្រះរាជក្រឹត នស/រកត/០៤១៣/៤១៦ ស្ដីពី ការដំឡើងឋានន្តរស័ក្តិ ជូនមន្ត្រីរាជការ ចំនួន ០៧ រូប របស់ក្រសួង ចំនួន ០៣ ពីឋានន្តរស័ក្តិវរមន្ត្រី ទៅឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ៤៣២០

២៧-៤-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៤១៣/៤១៧ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ លោកស្រី អស់លោក ជាមន្ត្រីរាជការ និងសប្បុរសជន ចំនួន ៥៥ រូប ៤៣២២

៣០-៤-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៤១៣/៤១៨ ស្ដីពី ការដំឡើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ឯក ជូនឯកឧត្តមឧត្តមសេនីយ៍ទោ ខូន សុវណ្ណា ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៤៣២៤

៣០-៤-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៤១៣/៤១៩ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ សប្បុរសជន ជាតិ និងអន្តរជាតិ និងនាយទាហាន កងពលតូចលេខ ៧០ ចំនួន ៥៤ រូប ៤៣២៥

៣០-៤-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៤១៣/៤២០ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ សប្បុរសជន នាយទាហាន កងពលតូចលេខ ៧០ និងនាយទាហាន នៃយោធភូមិភាគទី ២ ចំនួន ៧២ រូប ៤៣២៨

៣០-៤-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៤១៣/៤២១ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ថ្នាក់ដឹកនាំ និងសប្បុរសជន ចំនួន ០៤ រូប ៤៣៣១

៣០-៤-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៤១៣/៤២៤ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ព្រះសង្ឃ មន្ត្រីរាជការ និងសប្បុរសជន ចំនួន ០៩ អង្គ/ រូប ៤៣៣២

០១-៥-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៥១៣/៤២៥ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតួបការចំពោះ ឯកឧត្តម ស្រី ណូរី ៤៣៣៣

០១-៥-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៥១៣/៤២៦ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតួបការចំពោះ ឯកឧត្តម ជុំ ចឿន ៤៣៣៤

# II.រាជរដ្ឋាភិបាល

## ១.អនុក្រឹត្យ

២២-៤-២០១៣ -អនុក្រឹត្យលេខ ១៩៩ អនក្រ.បក ស្ដីពី បែបបទនៃការទទួលសិទ្ធិ និងកាតព្វកិច្ច ទាក់ទងនឹងស្ថានភាពទាំងប្រាំ នៃយោធិនអាជីព និងបទប្បញ្ញត្តិដោយឡែកចំពោះ នាយទាហានថ្នាក់ឧត្ដមសេនីយ៍ ៤៣៣៥
២២-៤-២០១៣ -អនុក្រឹត្យលេខ ២០០ អនក្រ.បក ស្ដីពី ការកាត់ដីទំហំ ១៦៧,៣៦ ហិកតា នៅស្រុក ជាំក្សាន្ដ ខេត្តព្រះវិហារ ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដី ឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៥២១ គ្រួសារ ៤៣៤៥
២២-៤-២០១៣ -អនុក្រឹត្យលេខ ២០១ អនក្រ.បក ស្ដីពី ការកាត់ដីសរុបទំហំ ២.៦២០ ហិកតា នៅស្រុកសណ្ដាន់ ខេត្តកំពង់ធំ ក្នុងនោះកាត់ចេញពីដីព្រៃសម្បទានរបស់ក្រុមហ៊ុន កូលិចស៊ីម និងកាត់ចេញពីដីដែលមានដីកាដកហូត និងធ្វើអនុបយោគជាដីឯកជន របស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជា កម្មសិទ្ធិជូនប្រជាពលរដ្ឋ និងផ្ដល់សិទ្ធិលើក្បាលដី ៤៣៤៨
២៣-៤-២០១៣ -អនុក្រឹត្យលេខ ២០២ អនក្រ.បក ស្ដីពី ការកាត់ដីសរុបទំហំ ១.៧៩៧ ហិកតា នៅស្រុកសង្គមថ្មី ខេត្តព្រះវិហារ ក្នុងនោះកាត់ចេញពីដីព្រៃសម្បទានរបស់ក្រុមហ៊ុន ធី.ភី.ភី និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ កាត់ចេញពីដីព្រៃសម្បទានសេដ្ឋកិច្ច របស់ក្រុមហ៊ុន ឆាណាហ្គ្រេតខស (ខេមបូឌា) អ៊ិនវេសមេន និងកាត់ចេញពីដី សម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ឌីស៊ីង ហាវេស (ខេមបូឌា) ខូ អិលធីឌី សម្រាប់ ធ្វើប្រទានកម្មជា កម្មសិទ្ធិជូនប្រជាពលរដ្ឋ ៥៤៧ គ្រួសារ និងរក្សាទុកមួយចំណែក សម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ៤៣៥១
២៣-៤-២០១៣ -អនុក្រឹត្យលេខ ២០៣ អនក្រ.បក ស្ដីពី ការកំណត់តំបន់សហគមន៍ លើផ្ទៃដីទំហំ ៦.០៤៨ ហិកតា ក្នុងតំបន់ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតនៅក្នុងឃុំកន្ទួត និងឃុំយាង ស្រុកជាំក្សាន្ដ ខេត្តព្រះវិហារ សម្រាប់ផ្ដល់ចែកជូនគ្រួសារយោធិន ចំនួន ១.៧០០ គ្រួសារ ក្នុងកងពលតូចអន្តរាគមន៍លេខ ៨ ៤៣៥៤
២៦-៤-២០១៣ -អនុក្រឹត្យលេខ ២០៤ អនក្រ.បក ស្ដីពី ការកាត់ដីទំហំ ៦១៦,១៤ ហិកតា នៅក្រុង សំរោង ខេត្តឧត្ដរមានជ័យ ចេញពីដីដែលមានដីកាដកហូត (អតីតដីសម្បទាន សេដ្ឋកិច្ចរបស់ក្រុមហ៊ុន វឿលហ្គ្រីន) និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ ធ្វើប្រទានកម្មជា កម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុកមួយចំណែក សម្រាប់ហេដ្ឋា រចនាសម្ព័ន្ធរូបវន្ត និងផ្ដល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី ៤៣៥៦

២៦-៤-២០១៣ -អនុក្រឹត្យលេខ ២០៥ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ៤៨៥,៨៥ ហិកតា នៅក្រុងសំរោង ខេត្តឧត្តរមានជ័យ ចេញពីដីដែលមានដីកាដកហូត (អតីតដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន វៀលហ្គ្រីន) និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជា កម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុកមួយចំណែក សម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី ៤៣៥៩

០១-៣-២០១៣ -អនុក្រឹត្យលេខ ២១៦ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៤៣៦២

០១-៣-២០១៣ -អនុក្រឹត្យលេខ ២១៧ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៤៣៦៤

០៤-៣-២០១៣ -អនុក្រឹត្យលេខ ២១៨ អនក្រ.តត ស្តីពី ការផ្ទេរប្រភេទក្របខ័ណ្ឌជូនមន្ត្រីរាជការ ៤៤០២

០៤-៣-២០១៣ -អនុក្រឹត្យលេខ ២១៩ អនក្រ.តត ស្តីពី ការតែងតាំងអគ្គនាយក និងសមាជិកក្រុមប្រឹក្សាភិបាលទូរគមនាគមន៍កម្ពុជា ៤៤០៣

០៤-៣-២០១៣ -អនុក្រឹត្យលេខ ២២០ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៤៤០៤

០៤-៣-២០១៣ -អនុក្រឹត្យលេខ ២២១ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៤៤០៥

០៤-៣-២០១៣ -អនុក្រឹត្យលេខ ២២២ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ៤៤០៦

០៤-៣-២០១៣ -អនុក្រឹត្យលេខ ២២៣ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៤៤០៧

០៤-៣-២០១៣ -អនុក្រឹត្យលេខ ២២៤ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៤៤០៨

០៤-៣-២០១៣ -អនុក្រឹត្យលេខ ២២៥ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៤៤១០

០៤-៣-២០១៣ -អនុក្រឹត្យលេខ ២២៦ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៤៤១២

០៤-៣-២០១៣ -អនុក្រឹត្យលេខ ២២៧ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៤៤១៣

០៤-៣-២០១៣ -អនុក្រឹត្យលេខ ២២៨ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៤៤១៤

០៤-៣-២០១៣ -អនុក្រឹត្យលេខ ២២៩ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិជូនមន្ត្រីរាជការ ៤៤១៦

០៥-៣-២០១៣ -អនុក្រឹត្យលេខ ២៣០ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ នាយទាហាន ៤៤១៨

០៥-៣-២០១៣ -អនុក្រឹត្យលេខ ២៣១ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៤៤២៦

០៥-៣-២០១៣ -អនុក្រឹត្យលេខ ២៣២ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៤៤២៧

០៥-៣-២០១៣ -អនុក្រឹត្យលេខ ២៣៣ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៤៤២៩

០៥-៣-២០១៣ -អនុក្រឹត្យលេខ ២៣៤ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ៤៤៣១


## ២-សេចក្តីសម្រេច


០៧-៥-២០១៣ -សេចក្តីសម្រេចលេខ ២០ សសរ ស្តីពី ការបង្កើតក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគម្រោងភាពជាដៃគូនៃជំនួយផ្នែកយុត្តិធម៌សហគមន៍នៅកម្ពុជា ៤៤៣២

ឃ

## III~ការងារបណ្ដាក្រសួង

### ទីស្ដីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

២៣-៤-២០១៣-ប្រកាសលេខ ១២៦ ប្រក.កសក ស្ដីពី ការបង្កើតតំបន់គ្រប់គ្រង និងអភិរក្សជីវចម្រុះដលផលទន្លេមេគង្គ ៤៤៣៩

# ព្រះរាជក្រឹត្យ

នស/រកត/០៤១៣/៤១៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាស ឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ដំឡើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ ជូនសពនាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ

**ក. ដំឡើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ឯក**

- ឧត្តមសេនីយ៍ទោ **សួរ ច័ន្ទហេង** អត្តលេខ ០០០១៩៧

**ខ. ដំឡើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ត្រី**

- វរសេនីយ៍ឯក **សែម យោ** អត្តលេខ ០០៨៥៨៦

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧.១៣០៤.៤១៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១៣

លេខ: ៤០៩ ច.ល
**ដើម្បីចម្លងចេញ**
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ២០១៣
**អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល**

**ស៊ុយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៣/៤១៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម ០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ ៖** ដំឡើងឋានន្តរស័ក្តិជូនមន្ត្រីរាជការចំនួន ០៧ រូប របស់ក្រសួងចំនួន ០៣ ពីឋានន្តរស័ក្តិវរមន្ត្រី ទៅឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល៖

| ល.រ | គោត្តនាម និង នាម | ភេទ | ឋានន្តរស័ក្តិ និង ថ្នាក់ចាស់ | ឋានន្តរស័ក្តិ និង ថ្នាក់ ត្រូវដំឡើង |
|---|---|---|---|---|
| **ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** | | | | |
| [illegible] | ម៉ិញ បានកុសល | ប | ពីវរមន្ត្រី ថ្នាក់លេខ ៧ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| **ក្រសួងព័ត៌មាន** | | | | |
| ១ | [illegible] ផល្លីន | ស | ពីវរមន្ត្រី ថ្នាក់លេខ ៧ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៦ |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

| ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | | | | |
|---|---|---|---|---|
| ១ | **អ៊ិត សុត្ថា** | ប | ពីវរមន្ត្រី ថ្នាក់លេខ ៥ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៥ |
| ២ | **សួស សុផល** | ស | ពីវរមន្ត្រី ថ្នាក់លេខ ៥ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៥ |
| ៣ | **ហាឡូ ប៊ុណ្ណារ៉ាក់** | ប | ពីវរមន្ត្រី ថ្នាក់លេខ ៥ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៥ |
| ៤ | **ប្រាក់ អន្ថារ៉ា** | ប | ពីវរមន្ត្រី ថ្នាក់លេខ ៧ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ៥ | **សរ សុវណ្ណា** | ប | ពីវរមន្ត្រី ថ្នាក់លេខ ៧ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៦ |

**មាត្រា ២ ៖** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ ៖** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៤ ៖** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នសរ. ១៣០៤.៤២១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១៣

លេខ: ៤១២ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ២០១៣
**អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៤១៣/៤១៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

## ប្រោសព្រះរាជទាន

**ចំពោះ**

លោកស្រី អស់លោកជាមន្ត្រីរាជការ និងសប្បុរសជនបានចូលរួមចំណែក
ក្នុងការអភិវឌ្ឍមូលដ្ឋានលើគ្រប់វិស័យនៅក្នុងស្រុកមេសាង ខេត្តព្រៃវែង

**នូវ**

**ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍:**

១-លោក **បេ ធារឡេង** ២-លោក **ម៉ែន ប៊ុនរិទ្ធ**
៣-លោក **លឹម ឡុង** ៤-លោក **អ៊ុក វណ្ណធី**
៥-លោក **សុក សារ៉េត** ៦-លោក **ឌីវ វុត្ថា**

**ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា:**

១-លោកស្រី **ព្រុំ ចន្ថា** ២-លោក **នុត សឿន**
៣-លោក **មុន្នី វរៈ** ៤-លោក **ស៊ិន សឿន**
៥-លោក **អ៊ឹង ប៊ុនសុវណ្ណ** ៦-លោក **យូ មី**
៧-លោក **សួរ ឌីម៉ា** ៨-លោក **គៀ សុវណ្ណា**
៩- លោក **នាង ចំរើន** ១០- លោក **អ៊ុំ វរៈ**

**គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន:**

១- លោក **ផាត សុផានិត** ២- លោកស្រី **ប៊ុត ថាវ**
៣- លោក **ជា សុខខេង** ៤-លោក **ម៉ឹង ហ៊ន់**
៥-លោក **អ៊ុំ សំអឿន** ៦-កញ្ញា **ចំរើន សុខលួន**
៧- លោកស្រី **ម៉ែន មរកត** ៨-លោក **សាក់ សុធី**
៩-លោក **ចេង ចំរើន**

**ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា:**

១-លោក **ម៉ាន់ សាមន** ២-លោក **បេ លីស្រេង**
៣-លោក **ហាក់ សេរីវុធ** ៤-លោក **ខឹម សាមាន**

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL ក្រសួងព្រះបរមរាជវាំង

៥-លោក **អ៊ូ យឹម** ៦-លោក **ហ៊ួត ស៊ាន**

៧-លោក **អ៊ុក វណ្ណថា** ៨-លោកស្រី **ចំរើន សុខឡែន**

៩-លោក **ឡៅ ប៊ុនខេង** ១០-លោក **ខួន វណ្ណារី**

១១-លោក **អៀង ចាន់ធឿន**

**ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ**

១-លោក **ផ្លុង អ៊ិត** ២-លោក **ហាង ជុំ**

៣-លោក **វ៉ា ឈឿន** ៤-លោក **ឈឹម ទ្រី**

៥-លោក **ទេព ម៉ុន** ៦-លោក **សែម សឿន**

៧-លោក **ផាត់ សុភា** ៨-លោក **ហែន សុជា**

៩-លោក **ស្រី សំណាង** ១០-លោក **ជូ វបុត្រ**

១១-លោក **ប៉ែន សាគុណា** ១២-លោក **ពៅ អូន**

១៣-លោក **ចាន់ វី** ១៤-លោក **ហ៊ាង សារ៉េត**

១៥-លោក **ខួន ចាន់ធឿន** ១៦-លោក **ហែន ឧត្តម**

១៧-លោក **សេង ឈរ** ១៨-លោក **ប៊ុត វណ្ណារដ្ឋ**

១៩-លោក **មឿង រិទ្ធ** ២០-លោក **យ៉ាន់ ស៊ាត**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧.១៣០៤.៤៤៤

លេខ: ៤១០ ច.ល

**ដើម្បីចម្លងចែក**

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១៣

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ ២០១៣

**អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៤១៣/៤១៩

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ដំឡើងឋានន្តរស័ក្តិថ្នាក់ ឧត្ដមសេនីយ៍ឯក ជូនឯកឧត្ដមឧត្ដមសេនីយ៍ទោ ខូន សុវណ្ណា អត្តលេខ ០៣៨២ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២ :** តែងតាំងឯកឧត្ដមឧត្ដមសេនីយ៍ឯក ខូន សុវណ្ណា ជាទីប្រឹក្សាក្រសួងមហាផ្ទៃ មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ៣ :** សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៩៨.១៣០៤.៤២៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣

លេខ: ៤១៥ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ២០១៣
**អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៤១៣/៤១៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហាភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

## ប្រោសព្រះរាជទាន

**ចំពោះ**

សប្បុរសជនជាតិ និងអន្តរជាតិ និងនាយទាហានកងពលតូចលេខ៧០ ចំនួន៥៤រូប មានគុណបំណាច់និងស្នាដៃល្អឆ្នើមក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ និងដែលបានជួយឧបត្ថម្ភជាសម្ភារៈនិងថវិកា ដល់អង្គភាពកងពលតូចលេខ៧០ សម្រាប់កសាងអង្គភាពនាពេលកន្លងមក ទទួលបានលទ្ធផលល្អប្រសើរ

**នូវ**

**ក-គ្រឿងឥស្សរិយយស ជាតូបការ**

១-ឯកឧត្តម ព្រុំ ម៉ល់
២-ឯកឧត្តម ស៊ិន សំណាង
៣-ឯកឧត្តម អ៊ុំ វណ្ណា
៤-លោកឧកញ៉ា យ៉ាង ស៊ុយសាំង
៥-លោកជំទាវ លី ហៀករតនា
៦-លោកជំទាវ អាន្នី សុខអាន
៧-លោកជំទាវ ឧកញ៉ា ទ៉ូវ គឹមសួគ៌
៨-លោកជំទាវ សុខ កែវ ច័ន្ទសារុន
៩-លោកជំទាវ សែម នឿន
១០-លោកជំទាវ ណុព្វ ស៊ីដារ៉ា

**ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍**

១-ឧត្តមសេនីយ៍ទោ វៀត ថា អត្តលេខ ០០១៣៧៤
២-ឧត្តមសេនីយ៍ទោ ឈួន យូ អត្តលេខ ០៣៧១៨៧
៣-ឯកឧត្តម សាប៊ូ អូហ្សាណា
៤-ឯកឧត្តម ហុង បញ្ញារិទ្ធ
៥-ឯកឧត្តម អ៊ុង អៀង
៦-លោកជំទាវ តាន់ ដល្លី
៧-វេជ្ជបណ្ឌិត នឹង យ៉ៅយ៉េន
៨-វេជ្ជបណ្ឌិត គង់ សំអេន

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

៩-វេជ្ជបណ្ឌិត ប៉ែន ហ៊ីន
១០-លោក សុខ សុធីរៈ
១១-លោក ជា មុនីឬទ្ធិ
១២-លោកវរសេនីយ៍ទោ តាំង លីទេង អត្តលេខ ០១០៩៥៦

**គ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍**

ឧត្តមសេនីយ៍ទោ ជា វណ្ណា អត្តលេខ ០៤៨១៣៩

**ឃ-គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេរីវឌ្ឍន៍**

DATUK CHUAH KIM SEAH

**ង-គ្រឿងឥស្សរិយយស សេនាជ័យសិទ្ធ**

១-លោកឧត្តមសេនីយ៍ត្រី ខែម និន អត្តលេខ ០០៣៨៩០
២-លោកឧត្តមសេនីយ៍ត្រី សេង ភាណុល អត្តលេខ ០០២៣២៣

**ច-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា**

១-លោកវរសេនីយ៍ទោ សុខ ជា
២-លោក ម៊ុន សុភល្យា
៣-លោក ឈុន វិបុល
៤-លោក វៀម ឧត្តម
៥-លោកស្រី និត្យរ៉ា លក្ខិណា
៦-លោក ជួន វិរៈថង
៧-កញ្ញា និត្យរ៉ា ឬទ្ធិនី
៨-កញ្ញា នរិន្ទ បញ្ញាសុភ័ក្ត្រ
៩-លោក ម៉ោ សុផល
១០-លោកស្រី កែវ ខេមរា
១១-លោកស្រី កែវ មុំ

**ឆ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា**

១-លោកជំទាវ រ័ត្ន ធីតា
២-លោក ហួរ សាម៉េត
៣-លោក សូ មេង
៤-លោកស្រី ឡុង ខ្លូតនាលី
៥-លោក ពិន សាវាន
៦-លោក ប៉ក់ វណ្ណៈ
៧-លោក ជា សម្បត្តិ
៨-លោក គឹម ទុឡ្សី
៩-លោក តិន ណារ៉ុង
១០-លោក ហួត រ៉ា
១១-កញ្ញា អ៊ួន សុភាព
១២-លោក កែវ ខេមរិន្ទ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

**ង-គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់មហាសេនា**

១-Mr KYO HYUNG LEE

២-Mr JUNG JAE LEE

៣-Mr BYUNG HYUNG HWANG

**ឈ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ**

១-លោក **ប្រា បញ្ញា**

២-លោក **ជា មុនីរតនា**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នសរកត.០៤១៣.៤២៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣

លេខ: ៤១៩ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៣

**អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៣/៤៧០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

ចំពោះ

សម្បុរសជន នាយទាហាន កងពលតូចលេខ៧០ និងនាយទាហាន នៃយោធភូមិភាគទី២ ដែលមានស្នាដៃ និង គុណបំណាច់ខ្ពស់ ក្នុងការបំពេញភារកិច្ច បម្រើជាតិមាតុភូមិ អស់រយៈពេលជាច្រើនឆ្នាំកន្លងមក ទទួលបានលទ្ធផលល្អប្រសើរ

នូវ

**ក-គ្រឿងឥស្សរិយយស ជាតូបការ**

-ឯកឧត្តម ប៉ែន អ៊ាន

**ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍**

១-លោកឧកញ៉ា ទន់ ម៉ិនថៃ
២-វរសេនីយ៍ឯក កែម ថន អត្តលេខ ០០៣៧៨៩
៣-វរសេនីយ៍ឯក ឯក ស៊ីម អត្តលេខ ០០១៤៣២
៤-វរសេនីយ៍ទោ សូ កែវផេង អត្តលេខ ០១៣៧៤៤
៥-វរសេនីយ៍ទោ ម៉ែន ផល្លី អត្តលេខ ០១៣៨៦៤
៦-វរសេនីយ៍ទោ អ៊ុយ យ៉ុង អត្តលេខ ០១៣៨៧៦
៧-វរសេនីយ៍ទោ ជា សុផល អត្តលេខ ០២៤៧០៦
៨-លោក អ៊ុន គូ
៩-លោកស្រី ឡឹក សាមី

**គ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍**

-ព្រះចៅអធិការ សួរ រិទ្ធី

**ឃ-គ្រឿងឥស្សរិយយសសម្តេចព្រះមហាក្សត្រីយានីព្រះស៊ីសុវត្ថិមុនីវង្សកុសុមៈនារីរ័ត្ន ថ្នាក់ មហាសេរីវឌ្ឍន៍**

-លោកជំទាវ ឧត្តមសេនីយ៍ទោ អ៊ុក ដារ៉ា

**ង-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា**

១-វរសេនីយ៍ទោ យុគ ឃីម អត្តលេខ ០៥៦៣៣៩
២-វរសេនីយ៍ទោ កែវ ឡឿន អត្តលេខ ០០៣០៨២
៣-វរសេនីយ៍ទោ ឆាយសាភឿន អត្តលេខ ០០៩៨៥៤

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

៤-វរសេនីយ៍ទោ ស្រី សំ អត្តលេខ ០០៩៨៤៨

៥-វរសេនីយ៍ទោ គឹម ថុន អត្តលេខ ០០៩៨៣៥

៦-វរសេនីយ៍ទោ ស៊ិន សុវណ្ណារ៉ា អត្តលេខ ០០៩៨៤៧

៧-វរសេនីយ៍ទោ ពេជ្រ សារិទ្ធ អត្តលេខ ០០១០៤១

៨-វរសេនីយ៍ទោ ឆាន់ សុជាតិ អត្តលេខ ០០៩៨៣៣

៩-វរសេនីយ៍ទោ ហ៊ុន ឌីណា អត្តលេខ ០១៨៦៧៨

១០-វរសេនីយ៍ទោ អ៊ុក សំអុន អត្តលេខ ០០៣០៧៩

១១-វរសេនីយ៍ទោ ប៉ែនរ៉ី អត្តលេខ ០១៨៦៨៤

១២-វរសេនីយ៍ទោ សៅ ស៊ាន អត្តលេខ ០១៨៦៩៣

១៣-វរសេនីយ៍ទោ ជួន ជារ៉ារិទ្ធ អត្តលេខ ០១៨៦៧១

១៤-វរសេនីយ៍ទោ លឹម ហួរ អត្តលេខ ០០៩៨៣៤

១៥-លោកស្រី មាស សុធា

១៦-លោកស្រី ហៀក គឹមហៀង

ខ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

១-វរសេនីយ៍ត្រី ឃឿន ឆេត អត្តលេខ ០១៨៦៨៨

២-វរសេនីយ៍ត្រី ទ៉ាន់ ទិវៈ អត្តលេខ ០១៨៧៤០

៣-វរសេនីយ៍ត្រី ម៉ែន រ៉ាម៉ុង អត្តលេខ ០០៩៨៤៩

៤-វរសេនីយ៍ត្រី ទ៉ា អិត អត្តលេខ ០១២៨៦៦

៥-វរសេនីយ៍ត្រី កែវ រ៉ី អត្តលេខ ០១៨៦៨៥

៦-វរសេនីយ៍ត្រី កែវ សុម៉ានី អត្តលេខ ០២៤៤៨១

៧-វរសេនីយ៍ត្រី ឆ៉ា សុខា អត្តលេខ ០០៩៨៣៧

៨-វរសេនីយ៍ត្រី ថ្លាង ប៊ុនណាត អត្តលេខ ០១៨៦៩៦

៩-វរសេនីយ៍ត្រី ស៊ុំ សុទ្ធ អត្តលេខ ០១៨៧៥៩

១០-វរសេនីយ៍ត្រី ឈឹម ផា អត្តលេខ ០៤១០៨៥

១១-វរសេនីយ៍ត្រី ជា សុវណ្ណារ៉ុង អត្តលេខ ០១៨៧១០

១២-វរសេនីយ៍ត្រី សៅ គ្រឿន អត្តលេខ ០០៤១៨៣

១៣-វរសេនីយ៍ត្រី ម៉ៅ ឃឿន អត្តលេខ ០០៤១៨៥

១៤-វរសេនីយ៍ត្រី ហ៊ឹម រិទ្ធ អត្តលេខ ០០៩៨៤៤

១៥-វរសេនីយ៍ត្រី ឈួន ប៊ុនធឿន អត្តលេខ ០០៤១៨៩

១៦-វរសេនីយ៍ត្រី គ្រួច ធី អត្តលេខ០០៤១៨៨

១៧-វរសេនីយ៍ត្រី ពេជ្រ ហុង អត្តលេខ ០០៣០៦៣

១៨-វរសេនីយ៍ត្រី ទ៉ាន សាទ៉ាត អត្តលេខ ០០៩៨៧០

១៩-អនុសេនីយ៍ឯក ថោង រី អត្តលេខ ០១៨៧៥៧

២០-ឧបាសិកា ប៉ែន វណ្ណា

ច-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ភិបឌិន្ទ

១-អនុសេនីយ៍ឯក សេន រ៉ិន អត្តលេខ ០១១៣៤៣

២-អនុសេនីយ៍ឯក នង សុផល អត្តលេខ ០០៩៨៥២

៣-អនុសេនីយ៍ឯក តី សុធន់ អត្តលេខ ០០៩៨៥៣

| | | | |
|---|---|---|---|
| ៤-អនុសេនីយ៍ឯក | ស៊ុន | សារឿន | អត្តលេខ ០០៩៨៥១ |
| ៥-អនុសេនីយ៍ឯក | ចក់ | ខេន | អត្តលេខ ០១៨៧០២ |
| ៦-អនុសេនីយ៍ឯក | ប្រាក់ | សុធី | អត្តលេខ ០១៨៦៩៩ |
| ៧-អនុសេនីយ៍ឯក | អ៊ូ | នី | អត្តលេខ ០១៨៦៦៧ |
| ៨-អនុសេនីយ៍ឯក | ហ៊ុយ | ហ៊ុត | អត្តលេខ ០៦៣៩០៦ |
| ៩-អនុសេនីយ៍ឯក | ជា | សំអុល | អត្តលេខ ០៦៣៨៩២ |
| ១០-អនុសេនីយ៍ឯក | អ៊ុំ | សៀប | អត្តលេខ ០១៨៧១៤ |
| ១១-អនុសេនីយ៍ឯក | ជឹម | ម៉េង | អត្តលេខ ០១៨៧១៥ |
| ១២-អនុសេនីយ៍ឯក | ពេជ្រ | សំបូរ | អត្តលេខ ០១៨៧៣៧ |
| ១៣-អនុសេនីយ៍ឯក | ឈន | តឿម | អត្តលេខ ០០៩៨៦៣ |
| ១៤-អនុសេនីយ៍ឯក | សេង | សារឿន | អត្តលេខ ០០៩៨៦៤ |
| ១៥-អនុសេនីយ៍ឯក | ស៊ឹង | សុផា | អត្តលេខ ០២៤៤៧៨ |
| ១៦-អនុសេនីយ៍ឯក | ហ៊ិ | ចន្ថា | អត្តលេខ ០១៨៧៦២ |
| ១៧-អនុសេនីយ៍ឯក | រ័ត្ន | ឆុន | អត្តលេខ ០២៨៥៥៣ |
| ១៨-អនុសេនីយ៍ឯក | តួង | សុផាត | អត្តលេខ ០១៨៧៦១ |
| ១៩-អនុសេនីយ៍ឯក | សុខ | ចណ្ណារី | អត្តលេខ ០២៨៥៥៩ |
| ២០-អនុសេនីយ៍ឯក | អ៊ិន | សុធា | អត្តលេខ ០៣០១៦០ |
| ២១-អនុសេនីយ៍ឯក | រស់ | សាថន | អត្តលេខ ០២៨៤៦២ |
| ២២-អនុសេនីយ៍ឯក | យិន | ចយ | អត្តលេខ ០០៩៨៦៦ |
| ២៣-អនុសេនីយ៍ឯក | លុយ | ផា | អត្តលេខ ០០៩៨៧១ |
| ២៤-វរសេនីយ៍ត្រី | ខ៊ាន់ | អិត | អត្តលេខ ០១៨៦៩៥ |

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

[illegible] ១៣០៤.៤២៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣

លេខៈ ៤១៨ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០១៣

**អគ្គលេខាធិការរងនៃរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៣/៤២១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**ចំពោះ**

ថ្នាក់ដឹកនាំនិងសប្បុរសជន ចំនួន០៤រូប មានស្នាដៃល្អក្នុងការចូលរួមជួយកសាង
សមិទ្ធផលនានា នៅក្នុងឃុំសំរោងលើ ស្រុកអង្គស្នួល ខេត្តកណ្តាល កន្លងមក

**នូវ**

**ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា**

**១-ឯកឧត្តម ស្រ៊ុន ដារិទ្ធិ**

**២-លោក រ័ត្ន សុគះ**

**ខ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា**

**លោក អ៊ូម ចាន់តក្កី**

**គ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា**

**លោក នូ ម៉ុនសារិទ្ធ**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៧១៧.១៣០៤.៤២៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣

លេខ: ៤១៦ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែឧសភា ឆ្នាំ២០១៣

**អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៤១៣/៤៧៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ព្រះសង្ឃ មន្ត្រីរាជការ និងសប្បុរសជន ចំនួន ០៩អង្គ/រូប
ដែលមានគុណបំណាច់យ៉ាងធំធេងក្នុងការបម្រើជាតិ មាតុភូមិ

នូវ

ក- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :

១- លោក លី ណារិទ្ធ ២- លោក ហៀង សុខហួត

ខ- គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ :

១- លោក គិត ទ្រី

គ- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ :

១- ព្រះតេជគុណឥន្ទត្ថេរោ នៅ សុគន្ធថៃ ២- ឯកឧត្តម ម៉ៅ សោភ័ណ

ឃ- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា :

១-លោកវរសេនីយ៍ទោ សួង សំអឿន

ង- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ សេនា :

១- លោកអនុសេនីយ៍ឯក មាស សាខេន ២- លោកអនុសេនីយ៍ឯក ខង សាខេត

៣- លោកស្រី សៅ ថាង

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពាទស.១៣០៤.៤២៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣

លេខ: ៤១៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែឧសភា ឆ្នាំ២០១៣
អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល

ស៊យ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៣/៤៤៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ជាតូបការ

ចំពោះ

ឯកឧត្តម ស្រី ឈ្វីរី

ដែលបានខិតខំយកចិត្តទុកដាក់ក្នុងការបំពេញភារកិច្ច ថ្វាយ ព្រះមហាក្សត្រ
និងក្នុងព្រះរាជពិធីបុណ្យថ្វាយ ព្រះករុណា ព្រះបរមរតនកោដ្ឋ
ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៥៧.១៣០៥.៤៣០

លេខៈ ៤២៧ ច.ល

**ដើម្បីចម្លងចែក**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១៣*

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែឧសភា ឆ្នាំ២០១៣
**អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៣/៤៤៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ជាតូបការ

ចំពោះ

ឯកឧត្តម ជុំ ធឿន
ដែលបានខិតខំយកចិត្តទុកដាក់ និងមានស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការរៀបចំ
ព្រះរាជពិធីបុណ្យថ្វាយ ព្រះករុណា ព្រះបរមរតនកោដ្ឋ
ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ព.រ.ល.១៣០៥.៤៣១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣

លេខៈ ៤២៦ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែឧសភា ឆ្នាំ២០១៣
**អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល**

**សួយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ១៩៥.អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# បែបបទនៃការទទួលសិទ្ធិនិងភាតព្វកិច្ចទាក់ទងនឹងស្ថានភាពនាំងប្រាំនៃយោធិនអាជីព និងបទប្បញ្ញត្តិដោយឡែកចំពោះនាយទាហានថ្នាក់ឧត្តមសេនីយ៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៧/នស/៩៤ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសោធននិវត្តន៍និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤០៦/០០៨ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីរបបសោធននិវត្តន៍និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ

- បានឃើញអនុក្រឹត្យលេខ២៩ អនក្រ.បក ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០០២ ស្តីពីបទវិន័យទូទៅសម្រាប់កងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ១១៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពីការអនុវត្តរបបសោធននិវត្តន៍និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិនអាជីពទាំងពីរភេទនៃកងយោធពលខេមរភូមិន្ទ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៣

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងលើកកម្ពស់ការទទួលខុសត្រូវក្នុងការអនុវត្តតួនាទី ភារកិច្ច ការធានាសិទ្ធិនិងផលប្រយោជន៍របស់យោធិនអាជីពនៃកងយោធពលខេមរភូមិន្ទ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលដៅកំណត់បែបបទនៃការទទួលសិទ្ធិនិងកាតព្វកិច្ចទាក់ទងនឹងស្ថានភាពទាំងប្រាំនៃយោធិនអាជីពនិងបទប្បញ្ញត្តិដោយឡែកចំពោះនាយទាហានថ្នាក់ឧត្តមសេនីយ៍ អនុលោមតាមមាត្រា៣៩នៃច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះយោធិនអាជីពនៃកងយោធពលខេមរភូមិន្ទ។

## ជំពូកទី២
## ស្ថានភាពទាំងប្រាំនៃយោធិនអាជីព

**មាត្រា ៤.-**

យោធិនអាជីពគ្រប់រូបស្ថិតក្នុងស្ថានភាពណាមួយដូចខាងក្រោមនេះ៖

១- ស្ថានភាពសកម្ម។
២- ស្ថានភាពអសកម្ម។
៣- ស្ថានភាពក្រៅតំណែង។
៤- ស្ថានភាពចូលនិវត្តន៍។
៥- ស្ថានភាពក្រៅក្របខ័ណ្ឌ។

## ផ្នែកទី១
## ស្ថានភាពសកម្ម

**មាត្រា ៥.-**

ស្ថានភាពសកម្ម ជាស្ថានភាពដែលយោធិនអាជីពកាន់កាប់មុខតំណែងតាមឋានន្តរសក្តិរបស់ខ្លួន។ ក្រៅអំពីសិទ្ធិ កាតព្វកិច្ច និងភារកិច្ចទទួលខុសត្រូវដូចមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ និងអនុក្រឹត្យលេខ២៩ អនក្រ.បក ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០០២ ស្តីពីបទវិន័យទូទៅ សម្រាប់កងយោធពលខេមរភូមិន្ទ យោធិនទទួលបានសិទ្ធិបន្ថែមៈ

១- ឈប់សម្រាកព្យាបាលជំងឺច្រើនដងមានរយៈពេលសរុបជាអតិបរមា៦(ប្រាំមួយ)ខែក្នុងអំឡុងពេល ១២(ដប់ពីរ)ខែ។

២- ឈប់សម្រាកលំហែមាតុភាពរយៈពេល៩០(កៅសិប)ថ្ងៃ។

៣- ឈប់សម្រាកពិសេសពីការងាររយៈពេលជាអតិបរមា៦(ប្រាំមួយ)ខែ ដោយៈ

- នៅទទួលបានបៀវត្សចំពោះតែការបណ្តុះបណ្តាល ការធ្វើវិក្រឹតការក្នុងផលប្រយោជន៍បម្រើសេវា នៃកងយោធពលខេមរភូមិន្ទ
- គ្មានបៀវត្ស ចំពោះការបណ្តុះបណ្តាល ការធ្វើវិក្រឹតការក្នុងផលប្រយោជន៍ឯកជន។

ស្ថិតក្នុងស្ថានភាពសកម្ម យោធិនអាជីពអាចប្រឡងចូលឬសុំផ្ទេរក្របខ័ណ្ឌទៅបម្រើការងារនៅក្រសួង ស្ថាប័នស៊ីវិលបាន ក្រោយពីមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងការពារជាតិនិងក្រសួង ស្ថាប័នពាក់ព័ន្ធ ដោយ ក្រសួង ស្ថាប័នដែលទទួល ត្រូវគិតគូរឱ្យបានសមរម្យពីឋានន្តរសក្តិនិងឋានៈមុខតំណែងរបស់សាមីខ្លួននៅក្នុង កងយោធពលខេមរភូមិន្ទ។

## ផ្នែកទី២
## ស្ថានភាពអសកម្ម

**មាត្រា ៦.-**

ស្ថានភាពអសកម្ម ជាស្ថានភាពបណ្តោះអាសន្នរបស់យោធិនអាជីពដែលមិនអាចកាន់កាប់មុខតំណែង តាមឋានន្តរសក្តិរបស់ខ្លួនក្នុងរយៈពេលលើសពី៦(ប្រាំមួយ)ខែឡើងទៅ ដោយសារហេតុផលណាមួយដូច ខាងក្រោមៈ

១- ការឈប់សម្រាកព្យាបាលជំងឺរយៈពេលវែង។

២- ការឈប់សម្រាកដោយមូលហេតុសុខភាពរយៈពេលលើសពី៦(ប្រាំមួយ)ខែ។

៣- ការឈប់សម្រាកដោយហេតុផលគ្រួសារ។

៤- ភាពទំនេរ។

៥- ការដកហូតមុខតំណែង។

**មាត្រា ៧.-**

ការឈប់សម្រាកព្យាបាលជំងឺរយៈពេលវែងអនុញ្ញាតឱ្យបានចំពោះយោធិនអាជីពកើតជំងឺរបេង សរសៃប្រសាទ មហារីក និងជំងឺដទៃទៀត តាមការវិនិច្ឆ័យរបស់វេជ្ជបណ្ឌិតជំនាញមានសមត្ថកិច្ច ដែលតម្រូវ

ឱ្យឈប់សម្រាកពីការងារ។ យោធិននោះមានសិទ្ធិទទួលបៀវត្សពេញរយៈពេល៣(បី)ឆ្នាំដំបូង និងសម្រាប់ ២(ពីរ)ឆ្នាំបន្តទៀត បៀវត្សឋានន្តរសក្តិត្រូវកាត់បន្ថយពាក់កណ្តាល។

**មាត្រា ៨.-**

ការឈប់សម្រាកដោយមូលហេតុសុខភាពលើសពី៦(ប្រាំមួយ)ខែ សំដៅដល់ការឈប់សម្រាករបស់យោធិនអាជីពដែលមានពិការភាពឬមានជំងឺអ្វីផ្សេងៗក្រៅពីជំងឺដូចមានបញ្ជាក់ក្នុងមាត្រា៧ខាងលើនេះ បន្ទាប់ពីអស់សិទ្ធិឈប់សម្រាកដូចមានចែងក្នុងចំណុច១ មាត្រា៥នៃអនុក្រឹត្យនេះ ហើយគ្មានលទ្ធភាពបម្រើការងារបន្តទៀត។

ក្នុងករណីឈប់សម្រាកដោយមូលហេតុសុខភាពរយៈពេលលើសពី៦(ប្រាំមួយ)ខែ បៀវត្សឋានន្តរ-សក្តិយោធិនអាជីពចាប់ពីអនុសេនីយ៍ឯកឡើងទៅ ត្រូវកាត់បន្ថយពាក់កណ្តាល។ ចំពោះយោធិនអាជីពចាប់ពីអនុសេនីយ៍ទោចុះរហូតដល់នាយទាហានរង បៀវត្សឋានន្តរសក្តិត្រូវកាត់បន្ថយ៤៥%(សែសិបប្រាំភាគរយ)ក្នុងរយៈពេលអតិបរមា៣(បី)ឆ្នាំ។ បើជំងឺនោះតម្រូវឱ្យធ្វើការព្យាបាលបន្ត យោធិនរូបនោះទទួលបានបៀវត្សពេញក្នុងរយៈពេល១(មួយ)ឆ្នាំ និងសម្រាប់២(ពីរ)ឆ្នាំបន្តទៀត បៀវត្សឋានន្តរសក្តិត្រូវកាត់បន្ថយពាក់កណ្តាល។

**មាត្រា ៩.-**

បើពិការភាពឬជំងឺបណ្តាលមកពីការបម្រើការងារ អ្នកជំងឺដូចមានចែងក្នុងមាត្រា៧និងមាត្រា៨ខាងលើនេះ រក្សាបានទាំងស្រុងនូវបៀវត្សរបស់សាមីជនរហូតដល់ពេលចូលនិវត្តន៍ឬរហូតដល់ពេលដាក់ចូលក្នុងស្ថានភាពបាត់បង់សមត្ថភាពការងារ។

**មាត្រា ១០.-**

យោធិនអាជីពដែលឈប់សម្រាកព្យាបាលជំងឺរយៈពេលវែងឬឈប់សម្រាកដោយសារមូលហេតុសុខភាពលើសពី៦(ប្រាំមួយ)ខែ នៅមានឈ្មោះក្នុងបញ្ជីអតីតភាពដើម្បីដំឡើងឋានន្តរសក្តិតាមអតីតភាពបាន។ បើការសម្រាកព្យាបាលជំងឺដោយមូលហេតុគ្រោះថ្នាក់ការងារ ឈ្មោះយោធិនត្រូវបានរាប់បញ្ចូលសម្រាប់ការដំឡើងឋានន្តរសក្តិតាមជម្រើស។

រយៈពេលនៃការឈប់សម្រាកបែបនេះ ត្រូវរាប់បញ្ចូលផងដែរនូវអតីតភាពសោធននិវត្តន៍ឬសោធនបាត់បង់សមត្ថភាពការងារ។

**មាត្រា ១១.-**

យោធិនអាជីពអាចអនុញ្ញាតឱ្យឈប់សម្រាកដោយហេតុផលគ្រួសារតាមការស្នើសុំរបស់ខ្លួនដោយមិនទទួលបៀវត្សក្នុងរយៈពេលម្តងៗមិនតិចជាង៦(ប្រាំមួយ)ខែ និងមិនលើសពី២(ពីរ)ឆ្នាំ ហើយអាចបន្តជាថ្មីបានដោយរយៈពេលសរុបទាំងអស់មិនត្រូវលើសពី៤(បួន)ឆ្នាំ សម្រាប់ថែទាំសហព័ទ្ធឬកូនដែលមានជំងឺរ៉ាំរ៉ៃធ្ងន់ធ្ងរ។

នៅពេលផុតរយៈពេលឈប់សម្រាកនេះ យោធិនសាមីត្រូវដាក់ពាក្យសុំចូលបម្រើការងារវិញ។

**មាត្រា ១២.-**

ភាពទំនេរ ជាស្ថានភាពរបស់នាយទាហានអាជីពដែលបានបម្រើការងារលើសពី១៥(ដប់ប្រាំ)ឆ្នាំ ក្នុងនោះយ៉ាងតិច៦(ប្រាំមួយ)ឆ្នាំ មានឋានៈជានាយទាហាន។ ក្នុងស្ថានភាពនេះ នាយទាហានសាមីអាចទទួលបានការអនុញ្ញាតឱ្យឈប់សម្រាកការងារបណ្តោះអាសន្នក្នុងសេវាកងទ័ពតាមសំណើរបស់ខ្លួនឬ

ការឈប់សម្រាកក្នុងភាពទំនេរនេះ អាចអនុញ្ញាតឱ្យរយៈពេលអតិបរមា៥(ប្រាំ)ឆ្នាំ ហើយអាចស្នើសុំជាថ្មីបាន។ ក្នុងរយៈពេលសម្រាកនោះ នាយទាហានទទួលបានបៀវត្សតែមួយភាគបីនៃបៀវត្សបច្ចុប្បន្ន។ ពេលវេលាសរុបក្នុងការឈប់សម្រាកក្នុងភាពទំនេរមិនអាចលើសពី១០(ដប់)ឆ្នាំបានទេ។

រយៈពេលឈប់សម្រាកនេះ ត្រូវបានរាប់បញ្ចូលតែចំនួនពាក់កណ្តាលសម្រាប់អតីតភាពដំឡើងឋានន្តរសក្តិនិងចំនួនពេញសម្រាប់អតីតភាពសោធននិវត្តន៍។

មុខតំណែងនាយទាហានដែលឈប់សម្រាកក្នុងភាពទំនេរ ត្រូវបានជំនួសដោយអ្នកថ្មីក្នុងក្របខ័ណ្ឌ។ នាយទាហានសាមីអាចស្នើសុំចូលបម្រើការងារវិញបានគ្រប់ពេលវេលា ឬត្រូវបានអញ្ជើញឱ្យមកបម្រើការងារវិញនៅគ្រប់ពេលដែលកាលៈទេសៈតម្រូវ។ នាយទាហានរូបនោះអាចស្នើសុំចូលនិវត្តន៍ឬដាក់ឱ្យចូលនិវត្តន៍ដោយបញ្ញត្តិ ក្នុងករណីដែលយោធិនសាមីមានសិទ្ធិទទួលរបបសោធននិវត្តន៍។

នាយទាហានថ្នាក់ឧត្តមសេនីយ៍ ឧត្តមនាវី និងនាយទាហានជំនាញឯកទេស ឬត្រៀមទៅបណ្តុះបណ្តាលជំនាញឯកទេស ពុំត្រូវបានអនុញ្ញាតឱ្យស្ថិតនៅក្នុងភាពទំនេរបានទេ។

**មាត្រា ១៣.-**

ការដាក់ឱ្យស្ថិតក្នុងភាពទំនេរតាមពាក្យស្នើសុំរបស់នាយទាហានអាជីពចាប់មានប្រសិទ្ធភាពនៅថ្ងៃទី០១ នៃខែបន្ទាប់ ក្រោយពីបានទទួលសេចក្តីសម្រេចដាក់ឱ្យស្ថិតក្នុងភាពទំនេរ។ នាយទាហានអាជីពដែលមានបំណងសុំបន្តភាពទំនេរ ឬសុំចូលបម្រើការងារវិញ ត្រូវដាក់ពាក្យស្នើសុំ២(ពីរ)ខែ មុនពេលផុតកំណត់នៃរយៈពេលស្ថិតក្នុងភាពទំនេរ។ នាយទាហានអាជីពណាដែលពុំបានដាក់ពាក្យសុំបន្តភាពទំនេរឬសុំចូលបម្រើការងាររបស់ខ្លួនវិញនៅថ្ងៃចុងក្រោយនៃភាពទំនេរ ត្រូវចាត់ទុកថាបោះបង់ចោលការងារ។

**មាត្រា ១៤.-**

នាយទាហានអាជីពស្ថិតក្នុងភាពទំនេរដែលបានដាក់ពាក្យស្នើសុំចូលបម្រើការងារឡើងវិញនៅពេលផុតកំណត់ ត្រូវស្ថិតក្នុងភាពទំនេររហូតដល់ពេលណាមានកន្លែងទំនេរសម្រាប់ធ្វើការវិញ។

ការចូលបម្រើការងារឡើងវិញមានអាទិភាពទទួលកន្លែងទំនេរសមស្របទៅនឹងឋានៈរបស់ខ្លួន។

សេចក្តីសម្រេចដាក់ឱ្យយោធិនអាជីពស្ថិតក្នុងភាពទំនេរឬឱ្យចូលបម្រើការងារឡើងវិញ ត្រូវកំណត់ដោយព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាស។

**មាត្រា ១៥.-**

ក្នុងពេលចាំបាច់ រដ្ឋមន្ត្រីក្រសួងការពារជាតិអាចអញ្ជើញជាបន្ទាន់នូវនាយទាហានដែលកំពុងឈប់សម្រាកដោយហេតុផលគ្រួសារ ឬដោយភាពទំនេរឱ្យចូលខ្លួនមកបម្រើការងារវិញ។

**មាត្រា ១៦.-**

ភាពទំនេរគ្មានបៀវត្សដោយបញ្ញត្តិ ត្រូវអនុវត្តចំពោះយោធិនអាជីពក្នុងករណីដូចខាងក្រោម៖

- យោធិនអាជីពដែលបោះបង់ការងារឬអវត្តមានដោយគ្មានច្បាប់អនុញ្ញាតរយៈពេល១៥(ដប់ប្រាំ)ថ្ងៃជាប់គ្នា លើកលែងតែយោធិនរូបនោះមានករណីពិសេសណាមួយ។ ក្នុងចន្លោះរយៈពេល១៥(ដប់ប្រាំ)ថ្ងៃដែលអវត្តមាន ប្រធានអង្គភាពត្រូវក្រើនរំលឹកយោធិនសាមីយ៉ាងហោចណាស់ពីរដងដែរ។
- យោធិនអាជីពដែលស្ថិតក្នុងការជំនុំជម្រះរបស់តុលាការពីបទល្មើសឧក្រិដ្ឋ ឬបទល្មើសមជ្ឈិមហើយដែលបានប្តឹងឧទ្ធរណ៍រហូតដល់ថ្ងៃចេញសាលដីកាចុងក្រោយបង្អស់។

រយៈពេលនៃការដាក់ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សដោយបញ្ញត្តិ ពុំអាចលើលពី៣(បី)ខែឡើយ។ នៅពេលផុតរយៈពេល៣(បី)ខែនេះ យោធិនអាជីពដែលពុំត្រឡប់ទៅបំពេញការងារវិញ ក្រោយពីមានការដាក់កំហិតឱ្យចូលធ្វើការតាមការកំណត់ចំនួនពីរដង យោធិននោះត្រូវលុបឈ្មោះចេញពីក្របខ័ណ្ឌ។

**មាត្រា ១៧.-**

ការដកហូតមុខតំណែង ជាស្ថានភាពអសកម្មដោយវិធានការវិន័យចំពោះយោធិនអាជីពដែលមានកំហុសផ្សេងៗដោយហេតុផលណាមួយដូចខាងក្រោម៖

- កិរិយាមារយាទមិនល្អ
- កំហុសធ្ងន់ធ្ងរក្នុងមុខងារឬមិនគោរពវិន័យ
- ធ្វើឱ្យខូចកិត្តិយសកងទ័ព
- ឈប់សម្រាកលើសពេលកំណត់ដោយគ្មានមូលហេតុ
- ត្រូវបានផ្តន្ទាទោសដោយតុលាការ។

**មាត្រា ១៨.-**

ការដកហូតមុខតំណែងដាក់ក្នុងស្ថានភាពអសកម្មមានរយៈពេលមិនលើសពី៣(បី)ឆ្នាំ។ នៅពេលផុតកំណត់នៃរយៈពេលដែលយោធិនអាជីពស្ថិតនៅក្នុងស្ថានភាពអសកម្មដោយការដកហូតមុខតំណែង ត្រូវដាក់យោធិនសាមីឱ្យនៅក្នុងស្ថានភាពសកម្មវិញ។

រយៈពេលអសកម្មនៃយោធិនអាជីពដោយការដកហូតមុខតំណែង មិនត្រូវយកមកគិតក្នុងការដំឡើងឋានន្តរសក្តិនិងសម្រាប់ការចូលនិវត្តន៍ឡើយ។ ស្ថិតក្នុងស្ថានភាពនេះ យោធិនសាមីមានសិទ្ធិទទួលត្រឹមតែ ៤៥%(សែសិបប្រាំភាគរយ)នៃប្រាក់បៀវត្សឋានន្តរសក្តិ។ ការដកហូតមុខតំណែងដោយដាក់ឱ្យស្ថិតនៅក្នុងស្ថានភាពអសកម្ម ត្រូវអនុវត្តចំពោះយោធិនអាជីពដែលមិនទាន់មានសិទ្ធិចូលនិវត្តន៍។

**មាត្រា ១៩.-**

ការឈប់សម្រាកក្នុងស្ថានភាពអសកម្ម ដូចមានចែងក្នុងចំណុច១ដល់៣ មាត្រា៦នៃអនុក្រឹត្យនេះ និងការកាត់បន្ថយប្រាក់បៀវត្សឋានន្តរសក្តិ ត្រូវសម្រេចដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ។

ការដកហូតមុខតំណែងក្នុងស្ថានភាពអសកម្ម និងការដាក់ឱ្យស្ថិតក្នុងស្ថានភាពសកម្ម ត្រូវសម្រេចតាមឋានានុក្រមឋានន្តរសក្តិនិងមុខតំណែង។

ប្រាក់សញ្ជ័យដែលបានកាត់ ត្រូវរក្សាទុកនៅក្នុងបេឡារបស់ក្រសួងការពារជាតិ។

## ផ្នែកទី៣
## ស្ថានភាពក្រៅតំណែង

**មាត្រា ២០.-**

ស្ថានភាពក្រៅតំណែង ជាស្ថានភាពរបស់យោធិនអាជីពដែលត្រូវបានដាក់មួយរយៈឱ្យនៅក្រៅអង្គដើមរបស់ខ្លួន ដើម្បីបំពេញមុខងារសាធារណៈណាមួយផ្សេងក្នុងរដ្ឋបាលស៊ីវិលឬមុខងារឯកជនណាមួយផ្សេងទៀត ដែលបម្រើឱ្យផលប្រយោជន៍សាធារណៈ។

៦/១០

ការតែងតាំងឱ្យទៅបំពេញភារកិច្ចក្រៅតំណែងត្រូវសម្រេចឡើងតាមសំណើរបស់បុគ្គលឬដោយបញ្ញត្តិសម្រាប់រយៈពេលអតិបរមា៥(ប្រាំ)ឆ្នាំ។ ក្នុងករណីដែលច្បាប់តម្រូវឱ្យបំពេញការងារបន្ត យោធិនសាមីត្រូវដាក់ពាក្យសុំសាជាថ្មី។

យោធិនអាជីពដែលត្រូវទៅបំពេញភារកិច្ចក្រៅតំណែង ត្រូវដាក់ពាក្យសុំតាមនីតិវិធីនៅក្រសួងការពារជាតិ ក្រោយពីបានទទួលការតែងតាំងមុខតំណែងថ្មី ឋានៈមុខតំណែងដើមរបស់យោធិនសាមីដែលត្រូវទៅបំពេញភារកិច្ចក្រៅតំណែងត្រូវជំនួសដោយអ្នកផ្សេង។

យោធិនសាមីដែលបំពេញការងារក្នុងស្ថានភាពក្រៅតំណែងនេះ នៅពេលចប់ភារកិច្ចឬដោយតម្រូវការចាំបាច់របស់ក្រសួងការពារជាតិ ត្រូវមកបម្រើការងារក្នុងអង្គភាពដើមវិញ។

**មាត្រា ២១.-**

យោធិនអាជីពដែលត្រូវបានតែងតាំងឱ្យបំពេញភារកិច្ចក្រៅតំណែង ត្រូវផ្អាកការទទួលបៀវត្សពីក្រសួងការពារជាតិដោយទទួលបៀវត្សនៅក្រសួង ស្ថាប័នថ្មី។

**មាត្រា ២២.-**

យោធិនអាជីពដែលបម្រើការងារក្រៅតំណែង ត្រូវស្ថិតក្រោមវិធាននៃលក្ខន្តិកៈសម្រាប់ការគ្រប់គ្រងមុខងារដែលខ្លួនកំពុងកាន់កាប់។

រយៈពេលដែលស្ថិតក្នុងស្ថានភាពក្រៅតំណែង ត្រូវរាប់បញ្ចូលនូវអតីតភាពសម្រាប់ការដំឡើងឋានន្តរសក្តិ និងគិតអតីតភាពការងារសម្រាប់ទទួលរបបសោធននិវត្តន៍ឬសោធនបាត់បង់សមត្ថភាពការងារផងដែរ។

យោធិនអាជីពដែលស្ថិតក្នុងស្ថានភាពក្រៅតំណែង ទទួលរបបសោធននិវត្តន៍នៅក្នុងអង្គដើមនៃកងយោធពលខេមរភូមិន្ទ។

## ផ្នែកទី៤
## ស្ថានភាពចូលនិវត្តន៍

**មាត្រា ២៣.-**

ស្ថានភាពចូលនិវត្តន៍ ជាស្ថានភាពបញ្ចប់ជាស្ថាពរនៃក្របខ័ណ្ឌយោធិនអាជីព ហើយត្រូវវិលត្រឡប់ទៅកាន់ជីវភាពស៊ីវិលវិញ ដោយទទួលផលប្រយោជន៍តាមច្បាប់ស្តីពីរបបសោធននិវត្តន៍និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០៧/នស/៩៤ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៤ និងច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីរបបសោធននិវត្តន៍និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៤០៦/០០៨ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៦។

យោធិនអាជីពអាចទទួលបានការអនុញ្ញាតច្បាប់ឈប់សម្រាកពី៦(ប្រាំមួយ)ខែដល់១២(ដប់ពីរ)ខែតាមលំដាប់ឋានន្តរសក្តិនិងតាមករណីចាំបាច់របស់យោធិនម្នាក់ៗមុនពេលចូលនិវត្តន៍។

## ផ្នែកទី៥
## ស្ថានភាពក្រៅក្របខ័ណ្ឌ

**មាត្រា ២៤.-**

ស្ថានភាពក្រៅក្របខ័ណ្ឌ ជាស្ថានភាពរបស់យោធិនដែលមានអាយុត្រូវចូលនិវត្តន៍ស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសោធននិវត្តន៍និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ០៧/នស/៩៤ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៤ តែត្រូវបានអនុញ្ញាតឱ្យបម្រើការងារបន្តទៀតក្នុងសេវា ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់កងយោធពលខេមរភូមិន្ទនិងសំណូមពររបស់យោធិនសាមីផង។

## ជំពូកទី៣
## បទប្បញ្ញត្តិដោយឡែកចំពោះនាយទាហានថ្នាក់ឧត្តមសេនីយ៍

**មាត្រា ២៥.-**

ស្ថានភាពនៃនាយទាហានថ្នាក់ឧត្តមសេនីយ៍ ត្រូវបែងចែកជាពីរផ្នែក៖

**ផ្នែកទី១** រួមមាននាយទាហានថ្នាក់ឧត្តមសេនីយ៍និងឧត្តមនាវីដែលស្ថិតនៅក្នុងស្ថានភាពសកម្ម អសកម្ម ក្រៅតំណែង និងក្រៅក្របខ័ណ្ឌ។

**ផ្នែកទី២** នាយទាហានថ្នាក់ឧត្តមសេនីយ៍និងឧត្តមនាវីដែលមិនស្ថិតនៅក្នុងផ្នែកទី១ តាមតម្រូវការចាំបាច់របស់រដ្ឋមន្ត្រីក្រសួងការពារជាតិ អាចត្រូវរក្សាទុកដើម្បីបំពេញការងារតាមតម្រូវការចាំបាច់របស់ប្រទេសជាតិ។

នាយទាហានថ្នាក់ឧត្តមសេនីយ៍និងឧត្តមនាវីទាំងពីរផ្នែក ត្រូវដាក់ឱ្យចូលនិវត្តន៍តាមច្បាប់ស្តីពីរបបសោធននិវត្តន៍និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ០៧/នស/៩៤ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៤ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីរបបសោធននិវត្តន៍និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៤០៦/០០៨ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៦។

**មាត្រា ២៦.-**

នាយទាហានថ្នាក់ឧត្តមសេនីយ៍និងឧត្តមនាវី អាចដាក់ឱ្យស្ថិតក្នុងស្ថានភាពទំនេរពិសេសបានតាមករណីដូចខាងក្រោម៖

១- ដោយបញ្ញត្តិសម្រាប់រយៈពេលមិនលើសពី១(មួយ)ឆ្នាំ ប្រសិនបើយោធិនសាមីរូបនោះមិនអាចកាន់កាប់មុខតំណែងតាមឋានន្តរសក្តិរបស់ខ្លួនក្នុងសេវារយៈពេលលើសពី៦(ប្រាំមួយ)ខែ។

២- ដោយការស្នើសុំរបស់សាមីខ្លួនសម្រាប់រយៈពេលយ៉ាងយូរ៦(ប្រាំមួយ)ខែ ប្រសិនបើយោធិនសាមីរូបនោះកំពុងកាន់កាប់មុខតំណែងណាមួយនៅក្នុងសេវា។

រយៈពេលស្ថិតក្នុងស្ថានភាពទំនេរពិសេសត្រូវរាប់បញ្ចូលក្នុងអតីតភាពសម្រាប់ការដំឡើងឋានន្តរសក្តិ និងសម្រាប់ការចូលនិវត្តន៍តែរយៈពេល៦(ប្រាំមួយ)ខែប៉ុណ្ណោះ។ ក្នុងស្ថានភាពនេះ នាយទាហានថ្នាក់ឧត្តមសេនីយ៍និងឧត្តមនាវីមានសិទ្ធិទទួលបៀវត្សពេញធម្មតារយៈពេល៦(ប្រាំមួយ)ខែ បន្ទាប់មក...

ពាក់កណ្តាលនៃបៀវត្សឋានន្តរសក្តិ។

នៅពេលផុតកំណត់រយៈពេលនៃស្ថានភាពទំនេរពិសេស នាយទាហានថ្នាក់ឧត្តមសេនីយ៍និងឧត្តម-នាវី អាចនឹងបញ្ចូលក្នុងផ្នែកទី១ឬផ្នែកទី២ ឬដាក់ឱ្យចូលនិវត្តន៍តាមយោបល់របស់គណៈកម្មាធិការក្រសួងការពារជាតិវាយតម្លៃលក្ខណសម្បត្តិនាយទាហាន ដែលត្រូវបង្កើតឡើងដោយក្រសួងការពារជាតិ។

**មាត្រា ២៧.-**

នាយទាហានថ្នាក់ឧត្តមសេនីយ៍និងឧត្តមនាវី ត្រូវដាក់ឱ្យនៅក្នុងផ្នែកទី១៖

- ដោយមិនកំណត់អាយុ ចំពោះនាយទាហានថ្នាក់ឧត្តមសេនីយ៍និងឧត្តមនាវីដែលជាមេបញ្ជាការបានដឹកនាំបញ្ជាកងទ័ពក្នុងពេលមានសង្គ្រាមឬបានបំពេញភារកិច្ចគួរឱ្យកត់សម្គាល់ក្នុងការបញ្ជាកងទ័ពចំពោះមុខសត្រូវ ឬជាអ្នកបានបណ្តុះបណ្តាលជំនាញជាន់ខ្ពស់

- ស្ថិតនៅក្នុងលក្ខណៈបណ្តោះអាសន្នចំពោះនាយទាហានថ្នាក់ឧត្តមសេនីយ៍និងឧត្តមនាវីដែលមានតួនាទីទទួលខុសត្រូវជាន់ខ្ពស់ ទោះបីហួសអាយុកំណត់ចូលនិវត្តន៍ក៏ដោយ។

**មាត្រា ២៨.-**

នាយទាហានថ្នាក់ឧត្តមសេនីយ៍និងឧត្តមនាវីត្រូវដាក់ឱ្យនៅក្នុងផ្នែកទី២បាន៖

១- តាមកាលកំណត់អាយុចូលនិវត្តន៍។

២- ដោយមុនកាលកំណត់អាយុចូលនិវត្តន៍៖

- តាមការស្នើសុំ ឬ
- ដោយបញ្ញត្តិ សម្រាប់មូលហេតុសុខភាពឬមូលហេតុផ្សេងៗ។

នាយទាហានថ្នាក់ឧត្តមសេនីយ៍និងឧត្តមនាវីដែលបានដាក់ទៅក្នុងផ្នែកទី២ ដោយមូលហេតុសុខភាព អាចបញ្ចូលទៅក្នុងផ្នែកទី១វិញបានតាមយោបល់របស់គណៈកម្មាធិការក្រសួងការពារជាតិវាយតម្លៃលក្ខណសម្បត្តិនាយទាហាន។

**មាត្រា ២៩.-**

នាយទាហានថ្នាក់ឧត្តមសេនីយ៍និងឧត្តមនាវីដែលស្ថិតក្នុងផ្នែកទី២ មានកាតព្វកិច្ចគោរពតាមបទប្បញ្ញត្តិដូចមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ និងអនុក្រឹត្យលេខ២៩ អនក្រ.បក ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០០២ ស្តីពីបទវិន័យទូទៅសម្រាប់កងយោធពលខេមរភូមិន្ទនិងទទួលបានបៀវត្សព្រមទាំងគោលរបបផ្សេងៗតាមឋានន្តរសក្តិនិងមុខតំណែងដើម។

**មាត្រា ៣០.-**

ពេលមានជំងឺ នាយទាហានថ្នាក់ឧត្តមសេនីយ៍និងឧត្តមនាវីចូលនិវត្តន៍ ត្រូវទទួលបានការព្យាបាលនៅតាមបណ្តាញសុខាភិបាលសាធារណៈឬយោធា ដោយថ្លៃសេវានៃការពិនិត្យព្យាបាលជារបស់រដ្ឋ។ ពេលទទួលមរណភាព ក្រសួងការពារជាតិទទួលបន្ទុករៀបចំពិធីបុណ្យសពតាមពិធីការយោធា។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា ៣១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខៈ** ៧០០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំ ១៦៧,៣៦ ហិកតា នៅស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ចេញពីដីគម្របព្រៃឈើ ឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋ ៥២១ គ្រួសារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ០២៦ គ.គ្រ.ដ.រ.ខ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តព្រះវិហារ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ផ្ទៃទំហំ ១៦៧,៣៦ ហិកតា ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិមរតកតេជោ ឃុំកន្ទួត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តព្រះវិហារ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ចំនួន ៥២១ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិមរតកតេជោ ឃុំកន្ទួត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ។

**មាត្រា ៣ .-**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តព្រះវិហារ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៧០១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីសរុបទំហំ ២.៦២០ ហិកតា នៅស្រុកសណ្តាន់ ខេត្តកំពង់ធំ ក្នុងនោះ កាត់ចេញពីដីព្រៃសម្បទានរបស់ក្រុមហ៊ុន ភូលិចស៊ីម និងកាត់ចេញពីដីដែលមានដីកាដកហូត និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋ និងផ្តល់សិទ្ធិលើក្បាលដី

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ១៧៥ ស.ណ.ក.ធ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ធំ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ដីសរុបទំហំ ២.៦២០ ហិកតា ក្នុងនោះ (១) ទំហំ ២.៥៧០ ហិកតា កាត់ចេញពីដីព្រៃសម្បទានរបស់ក្រុមហ៊ុន កូលិចស៊ីម និងទំហំ ៥០ ហិកតា កាត់ចេញពីដីដែលមានដីកាដកហូត និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មទំហំ ២.៦១៥,៨ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១.០៦៩ គ្រួសារ និងទំហំ ៤,២ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋនៅភូមិអូរពក ឃុំមានរិទ្ធិ ស្រុកសណ្តាន់ ខេត្តកំពង់ធំ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ២.-**

ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីសរុប ១.៤៧៧ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ១.៤៧១ ក្បាលដី ជូនប្រជាពលរដ្ឋ ១.០៦៩ គ្រួសារ អចលនវត្ថុរបស់វត្ត ០២ ក្បាលដី និងផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីសាធារណៈរបស់រដ្ឋ ០៤ ក្បាលដី (ដីសាលារៀន ០២ ក្បាលដី ប៉ុស្តិ៍រដ្ឋបាល ០១ ក្បាលដី និងទួលអ្នកតា ០១ ក្បាលដី) នៅភូមិអូរពក ឃុំមានរិទ្ធិ ស្រុកសណ្តាន់ ខេត្តកំពង់ធំ ។

**មាត្រា ៣.-**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ធំត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤..**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមេសា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

